**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាត្រូវបានបញ្ចប់ជាស្ថាពរហើយៗប្រជាកសិករបាននិងកំពុងខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម និងជំរុញការងារដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀតយ៉ាងសស្រាក់សស្រាំ ជាពិសេសការបង្កបង្កើនផលស្រូវរដូវប្រាំងរួមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មផងដែរ។ ជាការកត់សម្គាល់ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើង ៩១,១៧% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របី ៨,៨៣% ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ទន្ទឹមនឹងនោះថ្នាក់ដឹកនាំក្រសួងរួមទាំងអង្គភាពជំនាញដែលជាសេនាធិការបានចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀត ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួងយ៉ាងសកម្ម ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាព ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម។ ជាពិសេសការរៀបចំវេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួបផ្ទាល់ជាមួយផលិតករ សហគមន៍កសិកម្ម និងតួអង្គពាក់ព័ន្ធផ្សេងៗទៀតដែលបានចូលរួមប្រមាណ ៥០០នាក់ ដើម្បីស្វែងយល់ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្មឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះក៏ទទួលជួបសវនាការជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍តាមវិស័យនីមួយៗរួមទាំងការចូលរួមកិច្ចប្រជុំសំខាន់ៗទាំងក្នុង និងក្រៅប្រទេសជាច្រើនផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៥៧៤ ០០៣ហ.ត លើសឆ្នាំមុនចំនួន ៤១ ១៥២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ១៤ ១២៥ហ.ត ស្មើនឹង២,៤៦% និងដោយគ្រឿងយន្តមានចំនួន ៥៥៩ ៨៧៨ហ.ត ស្មើនឹង ៩៧,៥៤%

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

○ ផ្ទៃដីសាបសម្រេចបានចំនួន ៥៥៦ហ.ត តិចជាងឆ្នាំមុនចំនួន ៦០៧ហ.ត

○ ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ៥១៥ ៧៤០ហ.ត ស្មើនឹង ១១៨,៩០% នៃផែនការ ៤៣៣ ៧៥៥ហ.ត លើសឆ្នាំមុនចំនួន ២៩ ៦០៩ហ.ត។

### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំង

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៩៦ ៦៩១ហ.ត លើសឆ្នាំមុនចំនួន ៦ ៦៣០ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៨៤ ៩៥០ហ.ត ស្មើនឹង ១០៥,៥៤% នៃផែនការ ៨០ ៤៩៤ហ.ត លើសឆ្នាំមុនចំនួន ៧ ២៨០ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១១ ៧៤១ហ.ត ស្មើនឹង ៨២,៦២% នៃផែនការ ១៤ ២១០ហ.ត តិចជាងឆ្នាំមុនចំនួន ៦៥០ហ.ត។

### ១.៣ ការនាំចេញអង្ករ

ក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៦០ ៧៣១តោន ដែលមានការកើនឡើងចំនួន ៨ ៨១៩តោន (+១៧%) លើសបរិមាណនាំចេញរយៈពេល២ខែ ឆ្នាំ២០១៦ ដែលមានចំនួន ៥១ ៩១២តោន។ បរិមាណនាំចេញក្នុងខែកុម្ភៈនេះ បាននាំចេញទៅកាន់ទិសដៅចំនួន ៤១ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៤៦ ៣៨៧តោន) ប្រទេសបារាំងឈរលំដាប់ទី២ (១៥ ៣១៨តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៩ ១៣៦តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៤ (៦ ៣៨៦តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (៥ ១៧៩តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៦ (៣ ១០៦តោន) ប្រទេសឆែកឈរលំដាប់ទី៧ (៣ ០៥៧តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៨ (២ ៨៤៤តោន) ប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី៩ (២ ២៧៦តោន) និងប្រទេសអេស្ប៉ាញឈរលំដាប់ទី១០ (១ ៥៦៤តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៤១ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានប្រចាំខែនេះ (តោន) | បញ្ចេញលក់ប្រចាំខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ១៤៦ | - |
| **សរុប I** | | **៥៨៣** | **៧៧៦** | **១៤៦** | - |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១ ៩៥៧ | ១៥ ៣៨២ | ៣ ៩៨៥ | ៨០០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់ប៊ើលីមីធីត (រតនគិរី) | ១៣៩ | ២ ៥៥៨ | ៣៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ៣៤៣ | 84 |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៤ | ១ ០៩៩ | ២៥២ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ៨០៨ | ៣០០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសស៍ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ៨៤៥ | ៣៣២ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | - | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | - | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ១ 039 | ៦៣០ |
| **សរុប II** | | **៣១ ១៨២** | **៥៣ ៧៤៦** | **៨ ១៥៧** | **២ ៣៩៨** |

| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
|---|---|---|---|---|---|
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៨ ៩៦០ | ២២៣ ៧៥៨ | ៥ ៤០០ | ៥ ២០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៨៦ ៣៣១ | ១៥៤ ៤៥៤ | ១៤ ៧០០ | ១៤ ៥០០ |
| សរុប III | | ៩៥ ២៩១ | ៣៧៨ ២១២ | ២០ ១០០ | ១៩ ៧០០ |
| សរុប I+II+III | | ១២៧ ០៥៦ | ៤៣២ ៧៣៤ | ២៨ ៤០៣ | ២២ ០៩៨ |

- គួរកត់សម្គាល់ថា សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧នេះ តម្លៃកៅស៊ូក្នុងរង្វង់ ១ ៨០៣ - ១ ៩៩៥ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានរៀបចំទីតាំងស្រង់ទិន្នន័យជំងឺ Oidium នៅចម្ការកៅស៊ូក្រែក
- ចុះប្រមូលទិន្នន័យ និងវាស់ទំហំដើមតាមដានការលូតលាស់ចម្ការកៅស៊ូក្រែក
- ផ្ញើជំរឿនសម្ភារ ឧបករណ៍ និងសារធាតុគីមីមន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា
- ជំរឿនកូនកៅស៊ូងាប់ក្នុងឡូត៍ពិសោធន៍ IRAA012 និងច្បារពូជប្លុក២១
- ត្រួតពិនិត្យទូទៅលើការថែទាំច្បារពូជកៅស៊ូ និងស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ IRAA01-IRAA09
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ០៩ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពកៅស៊ូ SVR CV60
- បានសហការជាមួយអង្គការ UNIDO ដើម្បីធ្វើការជួសជុលឧបករណ៍ពិសោធន៍ក្នុងមន្ទីរពិសោធន៍ជាតិយថាប្រភេទ
- បានរៀបចំអត្ថបទស្រាវជ្រាវឥទ្ធិពលអ៊ីដ្រូកស៊ីលអាមីនស៊ុលផាតណឺត លើកៅស៊ូសន្លឹក
- ត្រួតពិនិត្យលើផ្ទាំងមុខចៀរ និងលាបថ្នាំរំញោចដើមកៅស៊ូ
- វិភាគ DRC តាមមេត្រូឡាក់ តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានបញ្ជូនគម្រោងចំនួន០២ ទៅកាន់ Mekong-Lancan Cooperation Conutries៖ (១)គម្រោងសិក្សាស្រាវជ្រាវនិងវាយតម្លៃលើគុណភាព និងសុវត្ថិភាពនៃផលិតផលធញ្ញជាតិ (២)គម្រោងសិក្សាស្រាវជ្រាវវាយតម្លៃការគ្រប់គ្រងផលិតផលកសិកម្ម និងចំណីអាហារ
- បានដំឡើង និងធ្វើតេស្តម៉ាស៊ីន Ultra Pure Water និងម៉ាស៊ីន UV-2601
- បានជួបប្រជុំជាមួយតំណាងការិយាល័យពាណិជ្ជកម្មនៃស្ថានទូតចិន ស្តីពីការងារពិសោធន៍ផលិតផលកសិកម្មនិងចំណីអាហារ
- បានលើកគម្រោងស្តីពី Linking farmer to the Market through the Contract Farming Mechanism ទៅក្រសួងការបរទេស
- បានបើកវេទិកាប្រជុំចរចាការអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងកសិករ និងក្រុមហ៊ុនដែលមានសមាសភាពចូលរួមចំនួន ១២០នាក់
- បានបណ្តុះបណ្តាលកសិករស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលមានសមាសភាពចូលរួមចំនួន ១៤០នាក់។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** មន្ត្រីជំនាញបានបន្តចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព មានការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយដៃគូពាក់ព័ន្ធ។

- **ការងារឡជីវឧស្ម័ន៖** បន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននិងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះសម្រេចបាន ៦១ឡ។ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់។
- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

### ៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ នេះ រាជធានី-ខេត្តចំនួន១០ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១ ៥២៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វបានចំនួន ០២ករណី ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៣៧៩,៥គីឡូក្រាម ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។
- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៥៥កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។
- **ការងារនីតិកម្មនិងវិវាទ៖** កំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត ក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វទៅតាមលំដាប់អាទិភាពមានជាអាទិ៍៖ សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងបានប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីរៀបចំចងក្រងអនុក្រឹត្យ និងសៀវភៅសម្រាប់ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

### ៤.៣ ការងារស្រាវជ្រាវ៖

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ជាក់ស្តែងក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន ៩០០វត្ថុវិភាគ។
- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១៣ក្បាល ក្នុងនោះគោបា១ក្បាល គោប្រាម៉ាន់កាត់៦ក្បាល គោជំទង់៣៨ក្បាល គោបៅដោះ២៩ក្បាល គោកំផែងសែន៣៩ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២៨៧ក្បាល ក្នុងនោះជ្រូកបា ៩ក្បាល ជ្រូកមេ៦០ក្បាល កូនជ្រូក១៤៤ក្បាល កូនជ្រូកលក់៤៥ក្បាល និងជ្រូកទុកបម្រុងចំនួន១០ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់

ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានចុះពិនិត្យទីតាំងជាក់ស្តែងលើផ្ទៃដីស្នើសុំអនុបយោគចំនួន ០១កន្លែងនៅខេត្តមណ្ឌលគិរី
- បានចុះពិនិត្យវាយតម្លៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ០៧ក្រុមហ៊ុន
- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ០២កន្លែង មានសមាជិកចំនួន ៣០០គ្រួសារ គ្របដណ្តប់លើផ្ទៃដីទំហំ ៧២៦ហ.ត ក្នុងនោះមានខេត្តរតនគិរី ០១កន្លែង គ្របដណ្តប់លើផ្ទៃដីទំហំ ៤៣២ហ.ត និងខេត្តកំពង់ធំ ០១កន្លែង គ្របដណ្តបលើផ្ទៃដីទំហំ ២៩៤ហ.ត
- បានចុះធ្វើការបែងចែកតំបន់សហគមន៍ព្រៃឈើអូចុងណាច (ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី)មានផ្ទៃដីទំហំ ៩៤៤ហ.ត និងសហគមន៍ព្រៃឈើពីងប្រង់ក្លង់ពេសថូ (ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី)មានផ្ទៃដីទំហំ ១ ១០៤ហ.ត
- បានកំពុងពិនិត្យលើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ០៤កន្លែង មានសមាជិកចំនួន ២៨៣គ្រួសារ មានផ្ទៃដីសរុបទំហំ ៥ ៥១៣ហ.ត នៅក្នុងឃុំស្រែអំពូម ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចំនួន ០៦ក្រុមហ៊ុន និងអតិថិជន ០២នាក់ រួមមានឈើហ៊ុបមូលចំនួន ៣ ៥៨៨ម៣ កូនឈើចំនួន ១២៣ ៩៤០ដើម អុសចម្រុះចំនួន ៥០៧ស្ទែរ និងជ័រទឹកចំនួន ២៩០តោន។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- ក្រុមអភិរក្សសត្វដំរីបានចុះសិក្សា និងបំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តិសរុបចំនួន ៤២គ្រឿងនៅតំបន់មានវត្តមានដំរីព្រៃនៅថ្មបាំង អារ៉ែង វាលតាភូ និងអូរកី ខេត្តកោះកុង និងពិនិត្យរកទីតាំងសមស្របសម្រាប់បំពាក់ម៉ាស៊ីនថតបន្ថែមទៀត
- បានផ្តល់ចំណីគោចំនួន ១ក្បាលដល់សត្វត្មាតសរុបចំនួន ០៨ក្បាលនៅឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ ដើម្បីធានាការរស់រានរបស់ត្មាត និងធ្វើការអង្កេតតាមដាន
- បានការពារសម្បុកសត្វត្រដក់តូចចំនួន ១០សម្បុក សត្វត្មាតចំនួន ០១សម្បុក ត្រយ៉ងចង្កំក ស ចំនួន ១៦សម្បុក រំពេទន្លេចំនួន ០៧សម្បុកដែលជាប្រភេទសត្វជិតផុតពូជនៅខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តសៀមរាប
- បានផ្តល់ជូនឧបករណ៍ និងសម្ភារសម្រាប់បង្អើលដំរី ដល់ប្រជាពលរដ្ឋចំនួន ០៥គ្រួសារដែលទទួលរងការបំផ្លាញដំណាំពីសត្វដំរីព្រៃ និងខូចខាតចេក ០៨គុម្ព ស្វាយ០៣ដើម ខ្នុរមច័ន្ទន៍ ០២ដើម ល្ហុង០៤ដើម នៅខេត្តកោះកុង និងខេត្តព្រះសីហនុ
- ក្រុមហ៊ុនចំនួន ៦បានគ្រប់គ្រងកសិដ្ឋានចំនួន ០៧ ដែលមានស្វាក្តាមសរុបចំនួន ៥៦ ១៥០ក្បាល និងនាំចេញចំនួន ៥៧៦ក្បាល។

### ៥.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៣២០ក្បាល (បក្សី ៥២ ប្រភេទ ថនិកសត្វ ៤៦ប្រភេទ និងល្មូន ១៤ប្រភេទ)។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥គីនៅអារ៉ែង ឆាយរាប តំបន់ស្ពានក្រពើស្ទឹងជាច់ ស្ទឹងខៀវ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់។ បន្ថែមលើនេះក្រុមការងារបានធ្វើការតាមដានពិនិត្យប្រចាំឆ្នាំនៅតំបន់អភិរក្សទាំងអស់បានរកឃើញក្រពើភ្នំចំនួន ១០ក្បាល ស្លាកស្នាម ១៧កន្លែង និងលាមកចំនួន ៣៨ដុំ និងបានលែងក្រពើភ្នំចំនួន ០៦ក្បាលនៅស្ទឹងកំពង់តាជ័យ ខេត្តកោះកុង ព្រមទាំងបានចែកប្រដាប់ ក្មេងលេង ២០ឈុត និងសៀវភៅរឿងនិទានពីបរិស្ថានចំនួន ០៧ក្បាលដល់សាលាបឋមសិក្សាភូមិពោធិបឹង។

### ៥.៤ ការងារដាំដើមឈើ

- ការចុះសិក្សាស្រាវជ្រាវ និងធ្វើសារពើភ័ណ្ឌទីតាំងដីសម្រាប់ការងារដាំឈើ

- ការងារថែទាំចម្ការឈើចាស់

- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ១២ ៩២៦ដើម និងចែកជូនប្រជាពលរដ្ឋចំនួន ៣ ០៣៥ដើម

- ក្រុមហ៊ុនដាំឈើដែគូសហការមានក្រុមហ៊ុន ស៊ីងបាយអូរចេក ដែលជាក្រុមហ៊ុនកូរ៉េបានឈូសឆាយដីបានចំនួន ១១៥ ហិកតា ត្រៀមដាំដុះនៅដើមរដូវភ្លៀងខាងមុខ។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេសលើក្រុមហ៊ុនចំនួន ០២

- ចុះសិក្សាអត្រាកែច្នៃឈើនៅរោងម៉ាស៊ីនអារ កែច្នៃឈើជូនក្រុមហ៊ុនចំនួន ០៤

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលលានទេវតាទៅបរទេសចំនួន ០១ក្រុមហ៊ុន ដែលមានបរិមាណសរុប ៣២ម³

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ០២ក្រុមហ៊ុន ប្រភេទឈើ Radiata និងឈើ MDF មានបរិមាណសរុប ២២២ម³

- បានចូលរួមកិច្ចប្រជុំជាមួយក្រុមទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ផែនការវិនិយោគព្រៃឈើ កិច្ចប្រជុំមានអ្នកចូលរួមចំនួន ២០រូប (មន្ត្រីជំនាញរដ្ឋបាលព្រៃឈើចំនួន ១៥រូប និងក្រុមទីប្រឹក្សាចំនួន ០៥រូប)។ កិច្ចពិភាក្សាមានគោលបំណងបីគឺ៖(១)បង្ហាញពីស្ថានភាព និងផែនការកម្មវិធីវិនិយោគព្រៃឈើ របស់ធនាគារពិភពលោក (២) ស្នើសុំមតិយោបល់និងធាតុចូលរបស់មន្ត្រីជំនាញរដ្ឋបាលព្រៃឈើក្នុងការរៀបចំផែនការវិនិយោគព្រៃឈើ និង(៣) ពិនិត្យតំបន់វិនិយោគផ្ទាល់ដែលតំបន់ទាំងនោះគ្រោងនឹងដាក់បញ្ចូល ទៅក្នុងផែនការវិនិយោគព្រៃឈើរបស់ធនាគារពិភពលោក។ ក្រុមទីប្រឹក្សាADB សហការជាមួយរដ្ឋបាលព្រៃឈើ នឹងបង្ហាញគម្រោងវិនិយោគចុងក្រោយដល់រដ្ឋបាលព្រៃឈើ ដើម្បីសុំការអនុម័តមុនឈានដាក់ជូនធនាគារពិភពលោកនាខែឧសភា ឆ្នាំ២០១៧។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ៣ ៤៧៥ ០៤៨ ៣៥៨រៀល និងចំណូលពីសេវាសាធារណៈចំនួន ៣៩៨ ៨២០ ២១៦រៀល និង៧ ៨១៧,៨៣ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១៧៦ករណី ដោយបញ្ជូនទៅតុលាការចំនួន ១៤១ករណីនិងពិន័យអន្តរការណ៍ចំនួន ៣៥ករណី

- ដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ៧៣ម³ ឈើអារចំនួន ៥២៦ម³ ឈើគ្រាក់គ្រញូងចំនួន ០២ម³ និង១៣០គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៤៨ក្បាល និង៦៧គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ១៣ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ៤៦០ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងចុះពង្រឹងការអនុវត្តច្បាប់ចំនួន ១២លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ជាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន ១៥០តោន សរុបរយៈពេល២ខែបានចំនួន ៤ ៩៤៥តោន ស្មើនឹង៤១,២១% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣ ៨៩៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ២៥ ៣០០តោន សរុបរយៈពេល២ខែបានចំនួន ៤៨ ៧៥០តោន ស្មើនឹង១៤,១៧% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ៦ ៥០០តោន សរុបរយៈពេល២ខែបានចំនួន ១៥ ០០០តោន ស្មើនឹង១០,៤២% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ០០០តោន។

៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨ ៣៥០តោន សរុបរយៈពេល២ខែបានចំនួន ១៥ ៨២៥តោន ស្មើនឹង១៤,៣៩% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៩៧៥តោន។

**៦.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ១០ ០៦៣តោន សរុបរយៈពេល២ខែបានចំនួន ១៩ ២១៣តោន ស្មើនឹង៩,២៧% នៃផែនការ ២០៧ ៣៦០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៩៦៣តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ១៦ ៥០០ក្បាល សរុបរយៈពេល២ខែបានចំនួន ២៥ ០០០តោន ស្មើនឹង ១០,០០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៨ ៦៥០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួនប្រមាណ ២២ ៥០០ ០០០កូន សរុបរយៈពេល២ខែបានចំនួន ៣៤ ៥០០ ០០០តោន ស្មើនឹង១៧,២៥% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួនប្រមាណ ១២ ៥០០ ០០០កូន។

**៦.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ៨ ៣០០តោន សរុបរយៈពេល២ខែបានចំនួន ១៤ ០០០តោន ស្មើនឹង១៧,០៧% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២ ៣៥០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន ១ ៣០០តោន សរុបរយៈពេល២ខែបានចំនួន ២ ១០០តោន ស្មើនឹង ២៦,២៥% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៥០០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៧ ៥០០ ០០០លីត្រ សរុបរយៈពេល២ខែបានចំនួន ១០ ២០០ ០០០តោន ស្មើនឹង ២០,៤០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន៣ ២០០ ០០០លីត្រ។

**៦.៤ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់ អនុវត្តបានចំនួន ១ ០៥០តោន សរុបរយៈពេល២ខែបានចំនួន ១ ៨៥០តោន ស្មើនឹង ១២,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១២០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៦៥០តោន សរុបរយៈពេល២ខែបានចំនួន ៩៥០តោន ស្មើនឹង១៩,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៧០តោន។

**៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៣៣៦ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣១៩ករណី និងសមុទ្រចំនួន ១៧ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ១៣៣ ៨២៣ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ១ ៦០២មាត់ បង្គោល/ចម្រឹងចំនួន ៨៤ ៩៥២ដើម ឧបករណ៍ឆក់ត្រីចំនួន ៧០គ្រឿង របាំងព្រួលប្រវែង ១ ០០២ម៉ែត្រ សម្រាស់ទំហំ ២២ ០៩៤ម៉ែត្រក្រឡា លបកែច្នៃ ៣០០គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៥ ៧០៥គ.ក្រ

- បានផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ៣៧វគ្គ ដោយមានអ្នកចូលរួមចំនួន ១ ៦៤៩នាក់

- គួរកត់សម្គាល់ថាក្នុងខែកុម្ភៈនេះ គណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាបបានបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការអញ្ជើញចូលរួមតាមឧទ្ទម្ភាគចក្រ និងការចាត់វិធានការយ៉ាងតឹងរឹងរបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី**។

**៦.៦ ការប្រមូលថវិកា**

- ចំណូលពីវិស័យជលផលសម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧ ចំនួន ៤១១ ១២០ ០០០ រៀល ស្មើនឹង ១៣,២២% នៃផែនការ ៣ ១៨២ ១២៥ ៤០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៨០ ៩៥០ ០០០រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះរៀបចំពិសោធន៍ នៅខេត្តកំពត និងសៀមរាប
- បានចុះប្រមូលព័ត៌មាន និងរៀបចំក្រុមពិភាក្សាជាមួយកសិករ ចំនួន៦០នាក់ នៅខេត្តកំពត
- បានចុះពិនិត្យមើលការងារពិសោធន៍ និងកៀរពង្រៀបដីដោយប្រព័ន្ធឡាស៊ែរ នៅស្ថានីយស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍ នៅខេត្តព្រះវិហារ
- បានចុះពិនិត្យស្រែបង្ហាញ នៅខេត្តតាកែវ
- បានចុះតាមដាន និងត្រួតពិនិត្យពិសោធន៍ នៅខេត្តតាកែវ និងកំពត
- បានចូលរួមប្រជុំពិភាក្សាការងាររៀបចំផែនការមេសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០
- បានចូលរួមកិច្ចប្រជុំត្រៀមសម្រាប់សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពចំណូលពីវិស័យកសិផល និងភាគរបរិស្ថាន។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៦ក្រុមហ៊ុន សរុបចំនួន ២២៧មុខ
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន ០៣ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៣ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៨ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ០៥ក្រុមហ៊ុនសរុបចំនួន ២២សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី និងខេត្តកំពង់ឆ្នាំង ដែលមានសមាសភាពចូលរួមសរុបចំនួន ១១៤នាក់។

### ៨.៤ ការងារអនុវត្តច្បាប់

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ១២ក្រុមហ៊ុន
- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៩ ០០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ០៧ អាជីវករលក់ដុំ និងលក់រាយចំនួន ០២ដេប៉ូ។

## ៩ ផ្នែករដ្ឋបាល

- ក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ៣០៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៩៧ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៧០ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨១៩ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥២ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ១៨ច្បាប់
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ

ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អប្រសើរ។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៨៧១នាក់ ក្នុងនោះនារីចំនួន ១ ៥១៧នាក់ ស្មើនឹង ២២% រួមមាន៖
- អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៦៧នាក់ ក្នុងនោះនារីចំនួន ៧៦៩នាក់ ស្មើនឹង ២៧%
- អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ៤ ១០៤នាក់ ក្នុងនោះនារីចំនួន ៧៤៨នាក់ ស្មើនឹង ១៨% (បានបញ្ចូលមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តរួចហើយ)
- ចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌមានចំនួន ០៤នាក់ ក្នុងនោះបោះបង់ការងារមានចំនួន ០២នាក់ និងលាឈប់ពីការងារចំនួន ០២នាក់
- ចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងចំនួន ០២នាក់
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ០៣នាក់
- ធ្វើលិខិតផ្តល់នីត្យានុកូលភាពជូនមន្ត្រីកសិកម្មបានចំនួន ៣១នាក់ នារីចំនួន ០៦នាក់
- បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន ១៥នាក់
- ចេញប្រកាសមន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ២៤នាក់ នារីចំនួន ០២នាក់
- ចេញប្រកាសមន្ត្រីរាជការចូលបម្រើនៅអង្គភាពដើមវិញចំនួន ១៣នាក់ នារីចំនួន ០៥នាក់
- បញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៣៤៤នាក់។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៨៧៨នាក់ (ស្ត្រី ៣១២នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦២១នាក់(ស្ត្រី ២១៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ២៥៧នាក់(ស្ត្រី ៩៦នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានបន្តការរៀបចំគុណភាពអប់រំទៅតាមលក្ខណវិនិច្ឆ័យទាំង៩របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានបន្តការកែតម្រូវកម្មវិធីសិក្សាឱ្យឆ្លើយតបនឹងទីផ្សារ បទដ្ឋានជាតិ អន្តរជាតិ
- បានចុះអនុស្សរណៈយោគយល់គ្នារវាងសាលាជាតិកសិកម្មព្រែកលៀប និងសាកលវិទ្យាល័យបច្ចេកវិទ្យា Rajamangala Isan ប្រទេសថៃ និងសាកលវិទ្យាល័យកសិកម្ម BOGOR នៃប្រទេសឥណ្ឌូនេស៊ី
- បានដឹកនាំគណៈប្រតិភូនៃសាកលវិទ្យាល័យបច្ចេកវិទ្យា Rajamangala Isan ប្រទេសថៃចុះទស្សនកិច្ចសិក្សានៅខេត្តព្រះសីហនុ ដើម្បីស្វែងរកឱកាសការងារសហការផ្នែកអប់រំ និងស្រាវជ្រាវ
- បន្តជួសជុលអគារសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាន និងបរិស្ថានចំនួន ០២ខ្នង។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៦-២០១៧ សរុបមានចំនួន ៧៨៦នាក់(ស្ត្រី ៣១៨នាក់) រួមមាន៖ និស្សិតអាហារូបករណ៍សរុប ៥៧៧នាក់ (ស្ត្រី ២៧១នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្ត្រី ៤៧នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយ DTRA ICEBP ដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍

- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល រយៈពេល១ឆ្នាំនៅប្រទេសជប៉ុន

- បានសហការជាមួយទីភ្នាក់ងារ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យទៅបន្តការសិក្សាថ្នាក់ នៅប្រទេសកូរ៉េ

- បានជួបពិភាក្សាជាមួយប្រតិភូសាកលវិទ្យាល័យ វ៉ាស៊ីនតោន ស្តីពីការរៀបចំសិក្សាគម្រោងចិញ្ចឹមគោយកទឹកដោះ នៅខេត្តកំពង់ចាម

- បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមាន ទីតាំងនៅជុំវិញខេត្តកំពង់ចាម

- បានបន្តសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលនិស្សិត ជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៥នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និង មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តម១ បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានបញ្ជូនមន្ត្រីសាស្ត្រាចារ្យចំនួន៩រូប ចូលរួមកិច្ចប្រជុំនិងសន្និសីទវិទ្យាសាស្ត្រផ្សេងៗ និង០៥រូបផ្សេងទៀត ចូលរួមវគ្គបណ្តុះបណ្តាលខ្លី រយៈពេលពី១សប្តាហ៍រហូតដល់៦ខែ នៅសាកលវិទ្យាល័យដៃគូនៅបរទេស ព្រមទាំងបាន សហការណ៍ជាមួយអង្គការ SEARCA និង គម្រោង HEQCIP បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការវ័យ ក្មេងចំនួន១៨នាក់ នៅខេត្តសៀមរាប ដើម្បីពង្រឹងសមត្ថភាពលើកគម្រោងសំណើស្រាវជ្រាវ សម្រាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ

- បានចុះអនុស្សរណៈយោគយល់ជាមួយអង្គភាពបីគឺៈ ១.វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ITC) ស្តីអំពីការបង្កើតនិង ប្រើប្រាស់ធនធានសិក្សាអេឡិចត្រូនិក ជាមួយសាកលវិទ្យាល័យកសិកម្មបូហ្គ ២.ប្រទេសឥណ្ឌូនេស៊ី (Bogor Agriculture University) ស្តីអំពីការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងការស្រាវជ្រាវរួមគ្នា ៣.ជាមួយអង្គការ KOPIA និងRotary International Club ស្តីពីការគាំទ្រដល់កម្មវិធីចិញ្ចឹមមាន់និងការដោះស្រាយជីវភាពគ្រួសារ

- បានទទួលគណៈប្រតិភូបរទេស គ្រូនិងអ្នកជំនាញពីអឺរ៉ុបមកបំពេញបេសកកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីគាំទ្រដល់សកម្មភាពកិច្ចសហប្រតិបត្តិការគាំទ្រគម្រោង និងជំនាញវេជ្ជសាស្ត្រសត្វ ព្រមទាំងបានទទួលនិស្សិតនិង សាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Shinshu ប្រទេសជប៉ុន ដើម្បីប្រជុំពិភាក្សារៀបចំកម្មវិធីកម្មសិក្សានៅទីវាល និងការ ស្រាវជ្រាវរួមគ្នា

- មន្ត្រីសាស្ត្រាចារ្យ និង និស្សិតបានបរិច្ចាកឈាមជូនមជ្ឈមណ្ឌលជាតិផ្តល់ឈាមបានចំនួន ២២២នាក់ និស្សិត នារីនៃមហាវិទ្យាល័យកសិឧស្សាហកម្មមួយរូប បានទទួលពានរង្វាន់អ្នកវិទ្យាសាស្ត្រវ័យក្មេង YES ពីក្រុមហ៊ុនហុងដាកម្ពុជា។

## IV-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយដោយសម្រេចបាន ១០៤,៩៧% លើសឆ្នាំមុនចំនួន ៣៧ ៦២៨ហ.ត (ស្មើនឹង ៥,១៧%)។ រីឯល្បឿននៃការបង្កបង្កើនផលស្រូវរដូវប្រាំងអនុវត្ត បានស្មើនឹង ១១៨,៩០% នៃផែនការ ៤៣៣ ៧៥៥ហ.ត។ ដោយឡែក ទិន្នផលស្រូវប្រាំងគិតជាមធ្យមទទួលបានចំនួន ៤,៣២៧តោន/ហ.ត លើសឆ្នាំមុនចំនួន ១២គ.ក្រ/ហ.ត។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំ របស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវប្រាំង ដោយគិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗ តាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ

ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការណែនាំក្នុងការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ ព្រមទាំងបានចេញសេចក្តីណែនាំទៅដល់អង្គភាពជំនាញក្រោមឱវាទសហការជាមួយគ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃ និងភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ។ ជាមួយនេះ ក្រសួងបានយកចិត្តទុកដាក់បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន រួមទាំងសហគមន៍កសិកម្មផងដែរក្នុងក្របខ័ណ្ឌក្រុមការងារទី៩ ដើម្បីរិះរកវិធានការតាមភារកិច្ចក្នុងការចូលរួមដោះស្រាយរាល់បញ្ហាប្រឈមលើការធ្លាក់ចុះតម្លៃស្រូវអង្ករនៅមូលដ្ឋាន។ ព្រឹត្តិការណ៍សំខាន់មួយទៀតគឺ ការរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួបផ្ទាល់ជាមួយផលិតករ សហគមន៍កសិកម្ម និងតួអង្គពាក់ព័ន្ធផ្សេងៗទៀតដែលមានអ្នកចូលរួមប្រមាណ ៥០០នាក់ ដើម្បីស្វែងយល់ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្មឆ្លើយតមទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យតាមច្រកសំខាន់ៗនៅតាមព្រំដែន ដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស បន្តយកចិត្តទុកដាក់ពង្រឹងការផ្ទេរមុខងាររបស់ខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទៅថ្នាក់ក្រោមជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការតាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រគោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

## V- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦-២០១៧ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំ

ពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម ព្រមទាំងចេញសេចក្តីណែនាំឱ្យមានការប្រុងប្រយ័ត្នក្នុងការចូលរួមទប់ស្កាត់ភ្លើងឆេះព្រៃ និងឆេះស្រូវជាយថាហេតុ

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវទាន់ពេលវេលា ចាត់ចែងជាបន្តក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរិលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព

- ចុះពិនិត្យទីតាំងដើម្បីត្រៀមរៀបចំរុក្ខទិវានាពេលខាងមុខ។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- ចុះពិនិត្យទីតាំងដើម្បីត្រៀមរៀបចំមច្ឆទិវានាពេលខាងមុខ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិង

ទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ព្រមទាំងជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រតាមការចាំបាច់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទ ការចុះពង្រឹងភារកិច្ចក្នុងការបញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ត្រៀមរៀបចំសន្និបាតកសិករ និងសន្និបាតកសិកម្មទូទាំងប្រទេស ដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុ-អាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**